ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## សេចក្តីជូនដំណឹង

## ស្តីពីសិក្ខាសាលាពិគ្រោះយោបល់លើ

## “ការអនុវត្តផ្នែកប្រតិបត្តិការ និងការថែទាំ (Operation and Maintenance - O&M) គម្រោងកំពង់ផែទេសចរណ៍ខេត្តកំពត ក្រោមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន”

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហការជាមួយក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងទេសចរណ៍ នឹងរៀបចំសិក្ខាសាលាពិគ្រោះយោបល់ជាមួយវិនិយោគិនលើ “**ការអនុវត្តផ្នែកប្រតិបត្តិការ និងការថែទាំ** (Operation and Maintenance - O&M) **គម្រោងកំពង់ផែទេសចរណ៍ខេត្តកំពត ក្រោមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន**” ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២៣ វេលាម៉ោង ០៨:៣០ ព្រឹក នៅសណ្ឋាគារ ហៃយ៉ាត់ រីជិនស៊ី ភ្នំពេញ និងតាមរយៈប្រព័ន្ធវីដេអូ។ សិក្ខាសាលាពិគ្រោះយោបល់នេះ នឹងមានការអញ្ជើញចូលរួមពីវិស័យឯកជន ដូចជាប្រតិបត្តិករ កំពង់ផែទេសចរណ៍ក្នុងស្រុក តំបន់ និងអន្តរជាតិ ក៏ដូចជាក្រុមហ៊ុននាវាចរណ៍ និងក្រុមហ៊ុនវិនិយោគឯកជននានា ដើម្បីបង្កើតជាឱកាសក្នុងការពិភាក្សា និងផ្តល់មតិយោបល់លើការគម្រោងអភិវឌ្ឍន៍កំពង់ផែទេសចរណ៍ខេត្តកំពត សម្រាប់ គោលដៅនៃការអភិវឌ្ឍវិស័យទេសចរណ៍នៅតំបន់ឆ្នេរសមុទ្រក្នុងខេត្តកំពត ខេត្តកែប និងតភ្ជាប់គោលដៅទេសចរណ៍ ពីកម្ពុជាទៅកោះត្រល់ និងប្រជុំកោះនានាជុំវិញតំបន់ជាប់សមុទ្រ។

សិក្ខាសាលាពិគ្រោះយោបល់នេះ នឹងប្រព្រឹត្តទៅក្រោមការដឹកនាំរបស់ **ឯកឧត្តម ឱម ម៉ាក់ធារិទ្ធ អគ្គនាយក នៃអគ្គនាយកដ្ឋានភាពជាដៃគូរវាងរដ្ឋ និងឯកជន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**។ សិក្ខាសាលាពិគ្រោះយោបល់នេះ នឹងផ្តល់នូវព័ត៌មានពាក់ព័ន្ធគម្រោង, ព័ត៌មានទីផ្សារ, តម្រូវការផ្នែកបច្ចេកទេស និងប្រតិបត្តិការ, លក្ខខណ្ឌនៃការដេញថ្លៃ, និង ក្របខណ្ឌពេលវេលាក្នុងការរៀបចំអភិវឌ្ឍគម្រោងកំពង់ផែទេសចរណ៍ខេត្តកំពត។

ចំពោះក្រុមហ៊ុនឯកជន និងវិនិយោគិន ដែលមានចំណាប់អារម្មណ៍ចូលរួមសិក្ខាសាលាខាងលើអាចធ្វើការចុះឈ្មោះតាមរយៈ **លោក លឹម ឆវិទវិទូ** ដែលមានអ៊ីម៉ែល chharvitvitou.lim@gmail.com ឬតាមទូរស័ព្ទលេខ ០៧៧ ៨៧៧ ៥៣៣ ។

សូមស្កេន QR Code ខាងក្រោមនេះ ដើម្បីទាញយកឯកសារពាក់ព័ន្ធសម្រាប់កម្មវិធីសិក្ខាសាលាពិគ្រោះយោបល់នេះ៖